ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




រូបភាពពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍

## បច្ចុប្បន្នភាពគាំពារសង្គមកម្ពុជា: លេខ ៦

# ការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ) ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ

## សារបាន

តាមរយៈអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩, រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ មកពីគ្រួសារមានបណ្ណសមធម៌ ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងពីកូនក្នុងផ្ទៃ រហូតដល់អាយុក្រោម ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។ កម្មវិធីនេះ ត្រូវបានអនុវត្តក្រោមក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ចាប់ពីខែមេសា ឆ្នាំ២០២៤ តាមរយៈអនុក្រឹត្យលេខ ៣៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ទន្ទឹមនេះ, ក្រុមគោលដៅដទៃទៀត រួមមានកម្មការិនី, មន្ត្រីរាជការ, មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រី ដែលជាសមាជិក ប.ស.ស. ក៏ទទួលបានការឧបត្ថម្ភសាច់ប្រាក់រាជរដ្ឋាភិបាល ផងដែរ។

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែមេសា ឆ្នាំ២០២៥

ជាមួយនឹងការគិតគូរយ៉ាងមធ្យ័តលើការផ្តល់អត្ថប្រយោជន៍ជូនពលរដ្ឋគោលដៅ, រាជរដ្ឋាភិបាលបានសម្រេចដំឡើងកម្រិតប្រាក់ឧបត្ថម្ភទ្វេដង គិតចាប់ពីខែសីហា ឆ្នាំ២០២៣ ជូនក្រុមគោលដៅ ដែលជាស្ត្រី និងកុមារមកពីគ្រួសារមានបណ្ណសមធម៌ តាមរយៈអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ និងផ្តល់ការឧបត្ថម្ភមុនពេលសម្រាល និងក្រោយពេលសម្រាលជូនកម្មករនិយោជិតជាស្ត្រី ព្រមទាំងមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រី ដែលបានមកទទួលសេវាសុខាភិបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ តាមរយៈប្រកាសអន្តរក្រសួងលេខ ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។

ជាវឌ្ឍនភាព, គិតត្រឹមដំណាច់ឆ្នាំ២០២៤, រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះដែលមានបណ្ណសមធម៌ ចំនួន **៣៨ ៣០៣ នាក់** ដោយបានចំណាយថវិការដ្ឋប្រមាណ **៤៩ ប៊ីលានរៀល** និងសមាជិក ប.ស.ស. ចំនួន **១២៤ ៨១២ នាក់** ដោយបានចំណាយថវិការដ្ឋប្រមាណ **១០៦ ប៊ីលានរៀល**។

ជាមួយគ្នានេះ, ដោយប្រតិបត្តិតាមអនុសាសន៍ និងការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពផ្តល់ការឧបត្ថម្ភមុនពេលសម្រាល និងក្រោយពេលសម្រាលក្រោមកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ) ឆ្នាំ ដល់នគរបាល និងយោធិនជានារី, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដាក់ចេញនូវកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ) ឆ្នាំ ដែលអនុវត្តដោយ ប.ស.ស. ដើម្បីផ្តល់អត្ថប្រយោជន៍បន្ថែមដល់នគរបាលជានារី តាមរយៈ "**ប្រកាសអន្តរក្រសួងលេខ ០៣៥ ក.ប/ប្រ.ក ប.ស.ស. ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ ស្តីពីការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ**"។ កម្មវិធីនេះ នឹងគ្របដណ្តប់ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារជាស្ត្រីចំនួនប្រមាណ **៦ ៦៩៦ នាក់**។



ការដាក់ឱ្យអនុវត្តកម្មវិធីនេះ បង្ហាញអំពីឆន្ទៈ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់កិច្ចគាំពារដល់ពលរដ្ឋគ្រប់រូបដោយឈរលើគោលការណ៍ "**មិនបោះបង់ពលរដ្ឋណាម្នាក់**" និងរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍមូលធនមនុស្ស សំដៅលើកកម្ពស់សុខុមាលភាពសង្គម, សមភាព, និងកំណើនសេដ្ឋកិច្ច ឱ្យក្លាយប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

## គោលបំណង

កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ មានគោលបំណងចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក រួមចំណែកដោះស្រាយកង្វះអាហារូបត្ថម្ភ ព្រមទាំងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

## អត្ថប្រយោជន៍

រាជរដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភជូនមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដែលមកទទួលសេវាពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈជាដំណាក់កាល ដូចខាងក្រោម៖

**ដំណាក់កាលមុនសម្រាល៖** ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៨០ ០០០ រៀល ក្នុង ១(មួយ)លើក** សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន **៤(បួន)លើក** មុនពេលសម្រាលកូន។

**ដំណាក់កាលក្រោយសម្រាល៖** ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៨ ០ ០០០ រៀល ១(មួយ)លើក** ដែលផ្តល់ជាអតិបរមាចំនួន **១០(ដប់)លើក** ក្នុងនោះ **៣ ដង** នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង **៧ ដង** នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។

**ចំពោះប្រាក់ឧបត្ថម្ភពេលសម្រាលកូន**, មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ត្រូវទទួលបានប្រាក់ឧបត្ថម្ភមាតុភាព និងបើកផ្តល់ដោយក្រសួងសាមី (អនុលោមតាមអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភមាតុភាព ជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និង មន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព)។

**បន្ថែមពីនេះ**, មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ជាស្ត្រីត្រូវទទួលបានប្រាក់ឧបត្ថម្ភផងដែរ ក្នុងករណីរលូតកូនស្របតាមលក្ខខណ្ឌដែលបានកំណត់ និងករណីរំលូតកូនស្របតាមច្បាប់ស្តីពីការរំលូតកូន។

### ប្រតិបត្តិករ

បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ជាប្រតិបត្តិករបើកផ្តល់ប្រាក់ឧបត្ថម្ភក្រោមកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

### សម្រាប់ព័ត៌មានបន្ថែម

សូមធ្វើការទាក់ទងទូរសព្ទលេខ ៖ **១២៩៧ ឬ ០៩២ ២១៩ ៨៨៨ / ០១៥ ២១៩ ៨៨៨** រៀងរាល់ម៉ោងធ្វើការ